ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ០១ ប្រក៣

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលនៃសម័យប្រជុំគណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រី
## ថ្ងៃអាទិត្យ ២រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
## ត្រូវនឹងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១

នៅព្រឹកថ្ងៃអាទិត្យ ២រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង៨និង៣០នាទីព្រឹក នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំគណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

**១- សេចក្តីព្រាងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។**

**២- បញ្ហាផ្សេងៗ។**

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំគណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រីបានសម្រេច៖

### ១- សេចក្តីព្រាងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

សេចក្តីព្រាងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ត្រូវបានរៀបចំឡើងក្នុងបរិការណ៍ដែលពិភពលោកកំពុងប្រឈមមុខនឹងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ កាន់តែសាហាវ ស្មុគស្មាញ និងក្នុងទ្រង់ទ្រាយកាន់តែធំ ដែលបានបង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពសាធារណៈ វិស័យសេដ្ឋកិច្ចនិងសង្គម ព្រមទាំងជីវភាពរស់នៅជាប្រក្រតីរបស់មនុស្សជាតិ។

កន្លងមក ព្រះរាជាណាចក្រកម្ពុជាធ្លាប់បានឆ្លងកាត់ការផ្ទុះរាលដាលនៃជំងឺកូវីដ-១៩ ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ដែលបានទប់ស្កាត់និងបញ្ចប់ប្រកបដោយជោគជ័យនូវព្រឹត្តិការណ៍នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ចំនួនពីរលើកគឺ លើកទី១ហៅថា «ព្រឹត្តិការណ៍ ៣ វិច្ឆិកា ២០២០» និងលើកទី២ជាព្រឹត្តិការណ៍នៃការឆ្លងរាលដាលចូលក្នុងសហគមន៍ជាលើកដំបូងហៅថា «ព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា ២០២០»។ បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាកំពុងប្រឈមមុខនឹងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាលើកទី៣ ដែលហៅថា «ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១» ដែលមានសភាពធ្ងន់ធ្ងរនិងកាន់តែទ្រង់ទ្រាយធំជាងព្រឹត្តិការណ៍ពីរលើកមុនៗ។

សេចក្តីព្រាងច្បាប់នេះ កំណត់អំពីវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដែលត្រូវអនុវត្តដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ក្នុងពេលបច្ចុប្បន្ននិងពេលអនាគត សំដៅការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់នៃការឆ្លងជំងឺនេះ ចំពោះវិស័យសង្គមនិងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សេចក្តីព្រាងច្បាប់នេះ បង្កើតឱ្យមានមូលដ្ឋានគតិយុត្តមួយរឹងមាំនិងគ្រប់ជ្រុងជ្រោយបន្ថែមទៀត ដល់ការគ្រប់គ្រងស្ថានការណ៍នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សេចក្តីព្រាងច្បាប់នេះមាន ៦ជំពូក និង១៨មាត្រា ដែលមានចែងអំពីទោសប្បញ្ញត្តិ ហើយត្រូវបញ្ជូនទៅសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ។

## ២- បញ្ហាផ្សេងៗ

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានលើកឡើងថា៖

១. **រាជរដ្ឋាភិបាល** បានសម្រេចប្រគល់ភារកិច្ចជូនក្រសួងសុខាភិបាលរៀបចំកម្មវិធីដើម្បីចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនដល់កម្មករប្រមូលសំរាម អ្នករត់តាក់ស៊ី អ្នកបើកម៉ូតូកង់បី អ្នករត់ម៉ូតូឌុបនៅពេលខាងមុខនេះ។

២. **រាជរដ្ឋាភិបាល** បានសម្រេចប្រគល់ភារកិច្ចជូនឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាលជាតំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទៅទទួលយកវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដែលជាអំណោយរបស់អង្គការសុខភាពពិភពលោក (WHO) ដែលនឹងមកដល់ព្រះរាជាណាចក្រកម្ពុជាក្នុងពេលឆាប់ៗខាងមុខនេះ។

អង្គប្រជុំគណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១១ និង១៥ នាទី។

ថ្ងៃអាទិត្យ ២រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១